**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ**

# សុន្ទរកថា

## ឯកឧត្តមបណ្ឌិត តាវ សេងហួរ ទេសរដ្ឋមន្ត្រី អនុប្រធានទី ១ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងជាប្រធានគណៈកម្មាធិការជាតិប្រជាជននិងការអភិវឌ្ឍ នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងឱកាសបើកវេទិកាកសិករថ្នាក់ជាតិស្តីពី "ការរួមគ្នាស្វែងយល់ពីបម្រែបម្រួលអាកាសធាតុ ដើម្បីកសិកម្មប្រកបដោយនិរន្តរភាព"

**វិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមិនា ឆ្នាំ២០១០**

- **សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ**
- **លោក លោកស្រី សមាជិក សមាជិកា នៃអង្គវេទិកា ជាទីមេត្រី**

ថ្ងៃនេះ ក្នុងនាមរាជរដ្ឋាភិបាលដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំមានកិត្តិយស និងសេចក្តីសប្បាយរីករាយឥតឧបមាដោយបានចូលរួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងពិធីប្រកាសបើកវេទិកាកសិករថ្នាក់ជាតិស្តីពី **"ការរួមគ្នាស្វែងយល់ពីបម្រែបម្រួលអាកាសធាតុ ដើម្បីកសិកម្មប្រកបដោយនិរន្តរភាព"**។

ក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រៅលជ្រៅ និងកោតសរសើរដោយស្មោះចំពោះសហការីរបស់ខ្ញុំទាំងអស់ក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលបានសហការគ្នាយ៉ាងជិតស្និទ្ធជាមួយអង្គការការីតាសកម្ពុជា (Caritas Cambodia) អង្គការកាតូលិកនិងសង្គ្រោះអន្តរជាតិ (Catholic relief services) អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (The NGO Forum on Cambodia) និងអង្គការជើរេស៏កម្ពុជា (Geres Cambodia) ដែលបានរៀបចំឱ្យមានវេទិកាដ៏មានសារៈសំខាន់នេះឡើង។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាពិសេសលោក លោកស្រីដែលជាតំណាងកសិករមកពីបណ្តាខេត្តនានានៅទូទាំងព្រះរាជណាចក្រកម្ពុជា ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងអង្គវេទិកាដ៏មានសារៈសំខាន់នាថ្ងៃនេះ។

ដូចដែលយើងទាំងអស់គ្នាបានជ្រាបហើយថា សព្វថ្ងៃនេះ បរិយាកាសពិភពលោកមានការប្រែប្រួលគួរឱ្យព្រួយបារម្ភ។ ស្ថានភាពបែបនេះ បណ្តាលមកពីបាតុភូមិធម្មជាតិ និងជាពិសេសសកម្មភាពរបស់មនុស្សក្នុងយុគសម័យវិទ្យាសាស្ត្រមានការរីកចម្រើនយ៉ាងខ្លាំង។ ជាការពិត ការរីកចម្រើននៃវិទ្យាសាស្ត្រ បានធ្វើឱ្យការរស់នៅរបស់មនុស្សកាន់តែប្រសើរឡើង ប៉ុន្តែក៏មានការបំផ្លាញបរិស្ថានពិភពលោកខ្លាំងណាស់ដែរ ដោយបានបង្កឱ្យមានបាតុភូតអវិជ្ជមានជាច្រើន ដូចជា ការកើនឡើងនៃកំដៅផែនដី កំណើននីវ៉ូទឹកសមុទ្រ ការកើនឡើងគ្រោះមហន្តរាយធម្មជាតិផ្សេងៗរួមមាន ខ្យល់ព្យុះ ទឹកជំនន់ គ្រោះរាំងស្ងួត រញ្ជួយផែនដី ។ល។ ដែលជាហេតុធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស និងដំណើការអភិវឌ្ឍន៏សេដ្ឋកិច្ច ជាពិសេសធ្វើឱ្យប៉ះពាល់ដល់វិស័យកសិកម្ម។ ផ្ទុយទៅវិញ យើងក៏ត្រូវដឹងថា សកម្មភាពក្នុងវិស័យកសិកម្មក៏រួមចំណែកធ្វើឱ្យមានបម្រែបម្រួលអាកាសធាតុដែរ ព្រោះវត្ថុបាតុភូតទាំងអស់សុទ្ធតែមានទំនាក់ទំនងគ្នា។ សកម្មភាពក្នុងវិស័យកសិកម្មដែលរួមចំណែកឱ្យមានបម្រែបម្រួលអាកាសធាតុ មានដូចជា ការកាប់រានព្រៃឈើ ការប្រើថ្នាំកសិកម្ម ការប្រើជីកសិកម្ម ការប្រើប្រាស់ទឹកក្នុងការស្រោចស្រពជាដើម។ លើសពីនេះ វិស័យឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ ក៏ជាប្រភពចម្បងដែលនាំឱ្យមានបម្រែបម្រួលអាកាសធាតុ ប្រសិនបើយើងមិនបានគ្រប់គ្រង និងត្រួតពិនិត្យឱ្យសមស្របទៅតាមបទដ្ឋានបច្ចេកទេសត្រឹមត្រូវទេនោះ។

ដូច្នេះ ដើម្បីធ្វើឱ្យវិស័យកសិកម្មមាននិរន្តភាព យើងត្រូវគិតពីការជះឥទ្ធិពលនៃបម្រែបម្រួលអាកាសធាតុលើវិស័យកសិកម្ម និងគិតអំពីសកម្មភាពក្នុងវិស័យផ្សេងៗដែលរួមចំណែកធ្វើឱ្យមានបម្រែបម្រួលអាកាសធាតុដូចបានបញ្ជាក់ខាងលើ។ បញ្ហាបម្រែបម្រួលអាកាសធាតុ បានក្លាយទៅជាប្រធានបទដែលត្រូវបានលើកយកមកពិភាក្សាជាចាំបាច់ និងបន្ទាន់នៅគ្រប់ទីកន្លែងទូទាំងពិភពលោក។ ជាក់ស្តែងក្នុងក្របខណ្ឌអន្តរជាតិ យើងមានអនុសញ្ញា ពិធីសារ និងយន្តការជាច្រើនដើម្បីដោះស្រាយ កាត់បន្ថយ និងទប់ស្កាត់នូវបញ្ហាគ្រោះមហន្តរាយនានាដែលកើតឡើងជាយថាហេតុនៅក្នុងពិភពលោក។ កន្លងមក មានកិច្ចប្រជុំថ្នាក់អន្តរជាតិ ស្តីពី "**បម្រែបម្រួលអាកាសធាតុ**" ត្រូវបានប្រារព្ធឡើងនៅទីក្រុងកូប៉េនហាក (Cophenhagen) ប្រទេសដាណឺម៉ាក ដើម្បីពិភាក្សាគ្នាពីបញ្ហានេះក្នុងគោលបំណងស្វែងរកនូវដំណោះស្រាយរួមគ្នាមួយក្នុងការបញ្ចៀសបញ្ហាដ៏គ្រោះថ្នាក់។

ដោយឡែកព្រះរាជាណាចក្រកម្ពុជាយើង ជាប្រទេសដែលមានអំណោយផលដល់ផលិកម្មកសិកម្ម។ ប្រជាពលរដ្ឋប្រមាណជា ៨០ % ជាកសិករ ប្រកបរបរកសិកម្ម និងពឹងផ្អែកលើធនធានធម្មជាតិផ្សេងទៀត ដើម្បីចិញ្ចឹមជីវិត។ សុភាសិតបុរាណខ្មែរពោលថា "**ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ**" មានន័យថា តាំងពីបុរាណកាលមកប្រជាជាតិខ្មែរ បានកំណត់យកវិស័យកសិកម្មជាវិស័យចម្បងបំផុតសម្រាប់ទ្រទ្រង់ជីវភាពប្រចាំថ្ងៃ និងអភិវឌ្ឍន៍ប្រទេសជាតិ។ បាយ និងត្រី ជាស្បៀងយុទ្ធសាស្ត្រជាប្រពៃណីសម្រាប់ប្រជាជនយើង។ ដូច្នេះ ការប្រែប្រួលអាកាសធាតុ បានជះឥទ្ធិពលយ៉ាងខ្លាំងលើវិស័យកសិកម្ម ធនធានទឹក ជលផល សុខភាពមនុស្ស សត្វ ។ល។ ដែលនឹងបង្កឱ្យមានផលវិបាកដ៏ធ្ងន់ធ្ងរដល់សន្តិសុខស្បៀង និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ក្នុងខណៈដែលធនធានយើងនៅមាន

កម្រិតសម្រាប់ឆ្លើយតបឱ្យសមស្របទៅនឹងបញ្ហាបម្រែបម្រួលអាកាសធាតុទាំងផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និង ស្ថាប័នជំនាញ។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការដោះស្រាយ និងទប់ស្កាត់នូវបញ្ហាអវិជ្ជមានទាំងនេះ ហើយក្នុងនាមជាភាគីនៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិ **ស្តីពីការប្រែប្រួលអាកាសធាតុ និងពិធីសារក្យូតូ** កម្ពុជាក៏បានខិតខំអនុវត្តអនុសញ្ញា និងពិធីសារនេះផងដែរ ជាក់ស្តែងក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវវិធានការជាច្រើន ដែលគាំទ្រដល់ការអភិវឌ្ឍន៍ប្រកបដោយចិរភាព ដូចជាការអនុវត្តបណ្តាគម្រោងយន្តការអភិវឌ្ឍន៍ស្អាត ការជំរុញឱ្យមានការប្រើប្រាស់ថាមពលកកើតឡើងវិញ យុទ្ធនាការសន្សំសំចៃថាមពលអគ្គិសនី ការប្រើប្រាស់ប្រភពថាមពលពីសំណល់កសិកម្ម ជាពិសេសថាមពលជីវម៉ាស មានជាអាទ៍ អង្កាម និងជីវឧស្ម័នសម្រាប់ផលិតអគ្គិសនី និងការដាំស្លរនៅតាមតំបន់ជនបទ។ ក្នុងវិស័យព្រៃឈើ មានគម្រោងមួយចំនួនកំពុងអនុវត្តសំដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ តាមរយៈការបញ្ចៀសការបាត់បង់ព្រៃឈើ ការរិចរិលព្រៃឈើ ការដាំដុះព្រៃឈើ និងការអភិរក្សព្រៃឈើ។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញនូវវិធានការណ៍ជាអាទិភាពមួយចំនួនទៀតរួមមាន : ការរៀបចំគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្តីពីការប្រែប្រួលអាកាសធាតុ ការងារបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយនិងផែនការតាមវិស័យពាក់ព័ន្ធ ការរៀបចំមូលនិធិប្រែប្រួលអាកាសធាតុ ការកៀរគរធនធានសម្រាប់អនុវត្តគម្រោងបន្សាំ និងគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាពបច្ចេកទេសកិច្ចសហប្រតិបត្តិការ ។ល។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី** !

ទោះបីរាជរដ្ឋាភិបាលកម្ពុជា មានបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជាតែងបង្ហាញឱ្យឃើញពីឆន្ទៈនយោបាយខ្ពស់បំផុត ដើម្បីរួមចំណែកក្នុងកិច្ចប្រឹងប្រែងជាសាកលចំពោះការទទួលខុសត្រូវលើជោគវាសនានៃមនុស្សជាតិ និងដោះស្រាយបញ្ហាប្រែប្រួលអាកាសដោយឈរលើគោលការណ៍ចម្បង៧របស់អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ ខ្ញុំសូមអនុញ្ញាតគូសបញ្ជាក់បន្តិចថា រាជរដ្ឋាភិបាលកម្ពុជាដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ បានធ្វើឱ្យមានការអភិវឌ្ឍក្នុងក្របខណ្ឌជាតិ និងកិច្ចសហប្រតិបត្តិការជាអន្តរជាតិលើគ្រប់វិស័យ។ **ក្នុងក្របខ័ណ្ឌអន្តរជាតិ នៅខែធ្នូឆ្នាំ ១៩៩៥ កម្ពុជាបានចូលជាសមាជិកអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ នៅខែកក្កដា ឆ្នាំ២០០២ ចូលជាសមាជិកនៃពិធីសារក្យូតូ ហើយឆ្នាំ២០០២ដដែល បានដាក់របាយការណ៍លើកទី១ ជូនកិច្ចប្រជុំប្រចាំឆ្នាំលើកទី៨ នៃសមាជិកអនុសញ្ញានៅទីក្រុងញ៉ូដេលី ប្រទេសឥណ្ឌា។ ដោយឡែកក្នុងប្រទេស រាជរដ្ឋាភិបាល**

**តាមរយៈក្រសួងបរិស្ថាន បានបង្កើតការិយាល័យប្រែប្រួលអាកាសធាតុនៅ២០០៣ ហើយនៅខែមេសា ឆ្នាំ២០០៦ គណៈរដ្ឋមន្ត្រីបានអនុម័តអនុក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងនៅមានយន្តការជាច្រើនក្នុងការចូលរួមសប្រសម្រួល ដោះស្រាយ ទប់ស្កាត់ បញ្ហាខាងលើដូចជា ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៏វិស័យកសិកម្មនិងជនបទ គណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយជាដើម។ លើសពីនេះទៅទៀត ក៏មានការចូលរួមយ៉ាងសកម្មពីបណ្តាដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល វិស័យឯកជន ជាអាទិ៍រួមមាន អង្គការការីតាសកម្ពុជា (Caritas Cambodia) អង្គការកាតូលិកនិងសង្គ្រោះអន្តរជាតិ (Catholic relief services) អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (The NGO Forum on Cambodia) និង អង្គការជើរេស៏កម្ពុជា (Geres Cambodia) ។ល។**

ទោះបីមានការខិតខំប្រឹងប្រែជាសាកល ក៏ដូចជាការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងបណ្តាដៃគូអភិវឌ្ឍន៏ អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល វិស័យឯកជនយ៉ាងណាក៏ដោយ ក៏ទាមទារឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋគ្រប់រូបតាមរយៈការសិក្សាស្វែងយល់ ចូលរួមផ្សព្វផ្សាយចំណេះដឹងទៅនឹងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ ដូច្នេះ វេទិកានៅថ្ងៃនេះពិតជាឱកាសដ៏ពិសេសសម្រាប់យើងទាំងអស់គ្នាដើម្បីស្វែងយល់ រៀនសូត្រ ចែករំលែកបទពិសោធន៏ និងពិភាក្សាដោះស្រាយបញ្ហាលើប្រធានបទសំខាន់ៗឈានទៅផ្តល់អនុសាសន៏ជាក់ស្តែង ដែលអាចយកទៅប្រើប្រាស់សំដៅគាំទ្រដល់ដំណើការអភិវឌ្ឍដោយចិរភាពក្រោមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី**

ដើម្បីឱ្យវេទិកានេះបានទទួលនូវលទ្ធផលតាមការគ្រោងទុក ខ្ញុំសូមស្នើឱ្យអង្គវេទិកាទាំងមូលពិភាក្សាគ្នាដោយយកចិត្តទុកដាក់លើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ÷

១-ស្ថានភាពទូទៅនៃបប្រែបម្រួលអាកាសធាតុ

២-ផលប៉ះពាល់នៃបប្រែបម្រួលអាកាសធាតុដែលបានជួបប្រទះ និងផលប៉ះពាល់ដែលរំពឹងទុកថានឹងកើតមាននាពេលអនាគតចំពោះវិស័យកសិកម្ម។

៣-វិធានការ និងគោលនយោបាយរបស់រាជដ្ឋាភិបាល ក្នុងការកាត់បន្ថយ និងសម្របទៅនឹងបប្រែបម្រួលអាកាសធាតុចំពោះវិស័យកសិកម្ម។

៤-ការលើកឡើងនូវកង្វល់របស់កសិករ ដើម្បីចូលរួមក្នុងការរៀបចំផែនការរបស់អង្គការ សង្គមស៊ីវិល និងរាជរដ្ឋាភិបាលនាពេអនាគតចំពោះវិស័យកសិកម្ម។

៥-ការត្រៀមបង្ការ និងឆ្លើយតបទៅនឹងគ្រោះមហន្តរាយដែលបង្កឡើយដោយការប្រែប្រួលអាកាសធាតុចំពោះវិស័យកសិកម្ម។

ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាលដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានផ្តល់នូវជំនួយឧបត្ថមគាំទ្រយ៉ាងច្រើន និងការចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាកន្លងមក។ ជាពិសេស ខ្ញុំសូមថ្លែងអំណរគុណ ដ៏ស្មោះចំពោះគណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បណ្តាដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល វិស័យឯកជន ដែលបានធ្វើសកម្មភាពយ៉ាងសកម្មទាក់ទងទៅបញ្ហាបន្សាំការប្រែប្រួល អាកាសធាតុ សំដៅទប់ស្កាត់កាត់បន្ថយបញ្ហាខាងលើ និងចូលរួមចំណែកក្នុងការកាត់បន្ថយផលប៉ះពាល់លើវិស័យ កសិកម្ម ដែលជាកង្វល់ដ៏ធំរបស់ប្រជាកសិករ។

ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី សូមប្រកបដោយពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសបើកវេទិកាកសិករថ្នាក់ជាតិស្តីពី **"ការរួមគ្នាស្វែងយល់ពីបម្រែបម្រួលអាកាសធាតុដើម្បីកសិកម្ម ប្រកបដោយនិរន្តរភាព"** ចាប់ពីពេលនេះតទៅ។

**សូមអរគុណ** !